CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៨ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងផ្តល់ជូននូវកម្មវិធីអាហារ 'Great Plates Delivered' សម្រាប់មនុស្សវ័យចំណាស់

## *ភោជនីយដ្ឋាននិងអ្នកផ្តល់ចំណីអាហារក្នុងក្រុងត្រូវបានលើកទឹកចិត្តឱ្យចូលរួម*

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចនៅថ្ងៃនេះបានប្រកាសថានឹងផ្តល់ជូននូវសេវាដឹកជញ្ជូនអាហារតាមផ្ទះដោយឥតគិតថ្លៃសម្រាប់មនុស្សវ័យចំណាស់ក្នុងគោលបំណងជួយដល់មនុស្សពេញវ័យដែលមានហានិភ័យខ្ពស់នៃជំងឺកូវីដ-១៩និងផ្តល់នូវការជម្រុញសេដ្ឋកិច្ចសំខាន់ៗដល់ភោជនីយដ្ឋានក្នុងស្រុកក្នុងកំឡុងពេលមានជំងឺរាតត្បាតនេះ។ ទីក្រុងនឹងចេញនូវសំណើរសុំ (request for proposals) ដើម្បីធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ស្បៀងអាហារនៅឡុងប៊ិចឱ្យរៀបចំនិងខ្ចប់កញ្ចប់អាហារ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "នេះគឺជាឱកាសដ៏ល្អមួយដើម្បីគាំទ្រដល់មនុស្សវ័យចំណាស់នៅក្នុងសហគមន៍របស់យើងដែលកំពុងមានតំរូវការបំផុតនៅពេលនេះក៏ដូចជាជួយឧស្សាហកម្មសេវាកម្មម្ហូបអាហារដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារវិបត្តិសុខភាពសាធារណៈនេះ។"

កម្មវិធី Great Plates Delivered នឹងផ្តល់នូវអាហារបំប៉នដោយឥតគិតថ្លៃចំនួន ៣ ពេលជារៀងរាល់ថ្ងៃដល់អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំឬអ្នកដែលមានអាយុ ៦០-៦៤ ឆ្នាំដែលមានហានិភ័យខ្ពស់នៃជំងឺកូវីដ-១៩ក្នុងភាពជាដៃគូជាមួយអ្នកផ្តល់អាហារនិងភោជនីយដ្ឋានក្នុងក្រុង។

ភោជនីយដ្ឋាននិងអ្នកផ្តល់ចំណីអាហារដែលចាប់អារម្មណ៍ក្នុងការចូលរួមក្នុងកម្មវិធីនេះត្រូវបានលើកទឹកចិត្តឱ្យបំពេញដំណើរការស្នើសុំ។ អាទិភាពនៃការចូលរួមកម្មវិធីនឹងផ្តល់ជូនអាជីវកម្មដែលមានម្ចាស់នៅក្នុងស្រុកនិង/ឬមានប្រភពក្នុងស្រុក ដែលផ្តល់អាទិភាពដល់បុគ្គលិកក្នុងស្រុកនិងការរក្សាកម្មករ និងផ្តល់ម្ហូបអាហារដែលអាចដាក់នៅកន្លែងកកនិងយកមកកំដៅបាន ក៏ដូចជាឆ្លើយតបទៅនឹងបទដ្ឋានអាហារូបត្ថម្ភនិងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងចំណីអាហារដែលមានសុវត្ថិភាពដែលអនុលោមតាមគោលការណ៍ណែនាំរបស់រដ្ឋ។ ដើម្បីចូលរួមក្នុងការស្នើសុំម្ចាស់អាជីវកម្មដែលមានចំណាប់អារម្មណ៍សូមចូលទៅកាន់គេហទំព័ររបស់ផ្នែកទិញនៃក្រសួងគ្រប់គ្រងហិរញ្ញវត្ថុ។

រយៈពេលដាក់ពាក្យស្នើសុំនឹងចាប់ផ្តើមនៅថ្ងៃនេះទី ១៨ ខែឧសភានិងបិទនៅម៉ោង ១១ ព្រឹកថ្ងៃព្រហស្បតិ៍ទី ២១ ខែឧសភា។ ព័ត៌មានលម្អិតបន្ថែមនឹងផ្តល់ជូននៅក្នុងសំណើ។

ទីក្រុងនឹងជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀងអាហារក្នុងស្រុកជាច្រើនសម្រាប់ការចូលរួមក្នុងកម្មវិធីនេះស្របតាមគោលការណ៍លទ្ធកម្មរបស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្នរបស់សហព័ន្ធ (Federal Emergency Management Agency)។

កាលពីខែមុនលោកអភិបាលរដ្ឋ Newsom បានប្រកាសដាក់ចេញនូវគម្រោង "Great Plates Delivered: Home Meals for Seniors" ដំបូងបង្អស់នៅក្នុងប្រទេសដែលមានភាពជាដៃគូជាមួយនឹងស្រុក ក្រុង និងកុលសម្ព័ន្ធ។ កំណែរបស់ឡុងប៊ិចនៃកម្មវិធីនេះត្រូវបានរំពឹងថានឹងចាប់ផ្តើមនៅថ្ងៃទី ២៩ ខែឧសភាឆ្នាំ ២០២០ ហើយបន្តរហូតដល់ថ្ងៃទី ១០ ខែមិថុនាដែលជាពេលវេលាដែលអនុម័តដោយទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្នរបស់សហព័ន្ធ។ រដ្ឋកាលីហ្វ័រញ៉ាមានបំណងស្នើសុំការពន្យារពេលកម្មវិធីនេះដល់ខែកក្កដា។

ព័ត៌មានបន្ថែមអំពីរបៀបដែលពលរដ្ឋអាចដាក់ពាក្យស្នើសុំអាហារនឹងមាននៅថ្ងៃខាងមុខ។

ចំពោះសំណួរទាក់ទងនឹងសំណើរស្នើសុំសូមទាក់ទងទៅ rfppurchasing@longbeach.gov។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###